ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

## កម្ពុជា និងអង្គការសហប្រជាជាតិបន្តលើកកម្ពស់ កិច្ចសហប្រតិបត្តិការដ៏ល្អបច្ចុប្បន្ន

ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងលោកស្រី Pauline Tamesis អ្នកសម្របសម្រួលប្រព័ន្ធអ.ស.ប.ប្រចាំកម្ពុជា បានសម្តែងការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជា និងអង្គការសហប្រជាជាតិ ហើយមានការប្តេជ្ញាចិត្តដូចគ្នាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការដ៏ល្អបន្ថែមទៀត។

ក្នុងខណៈដែលលោកស្រី ចូលជួបជម្រាបលា នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី** បានសម្តែងការអបអរសាទរចំពោះការបញ្ចប់បេសកកម្មប្រកបដោយជោគជ័យរបស់លោកស្រី Pauline Tamesis នៅក្នុងប្រទេសកម្ពុជា និងបានអះអាងជាថ្មីម្តងទៀតពីការប្តេជ្ញាចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអ.ស.ប.ដូចបានបង្ហាញអោយឃើញក្នុងការរៀបចំកិច្ចសន្ទនាប្រចាំឆ្នាំជាមួយទីភ្នាក់ងារ អ.ស.ប. ប្រចាំកម្ពុជាដោយ**សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** លើកលែងតែឆ្នាំទៅ ដោយសារតែការរីករាលដាលនៃជម្ងឺកូវីដ១៩។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានសម្តែងការកោតសរសើរចំពោះទីភ្នាក់ងារអ.ស.ប.ប្រចាំកម្ពុជា ក្នុងការផ្តល់ ជំនួយដ៏មានតម្លៃ រួមមានជំនួយផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងប្រតិបត្តិការនានា ព្រមទាំងវ៉ាក់សាំងដ៏ច្រើនសន្ធឹកសន្ធាប់ តាមរយៈយន្តការ COVAX និងឧបករណ៍វេជ្ជសាស្ត្រផ្សេងទៀតដើម្បីជួយកម្ពុជាប្រយុទ្ធប្រឆាំងការរាតត្បាតជម្ងឺកូវីដ១៩។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីមោទនភាពរបស់កម្ពុជាដែលបានជាប់ចំណាត់ថ្នាក់លេខ២ ក្នុងតំបន់អាស៊ីប៉ា-ស៊ីហ្វិកសម្រាប់ការចាក់វ៉ាក់សាំង ប្រកបដោយជោគជ័យ ដែលនេះបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលបើកប្រទេសឡើងវិញចាប់តាំងពីខែវិច្ឆិកាឆ្នាំទៅ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណចំពោះការគាំទ្ររបស់អ.ស.ប.ដល់ប្រទេសកម្ពុជា ដែលបានក្លាយជាអ្នកចូលរួមចំណែកដ៏សំខាន់ដល់បេសកកម្មថែរក្សាសន្តិភាពរបស់អ.ស.ប. នៅទូទាំងពិភពលោក ដោយបានបញ្ជូនកងកម្លាំង

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

រក្សាសន្តិភាពរបស់កម្ពុជាជាង៨០០០នាក់ចូលរួមក្នុងបេសកកម្មចំនួន១១ ក្នុងប្រទេសចំនួន៩ តាំងពីឆ្នាំ២០០៦មក ដែលបានធ្វើឲ្យកម្ពុជាជាប់ចំណាត់ថ្នាក់ទី២៨ ក្នុងចំណោមប្រទេសចូលរួមចំនួន ១២២ និងចំណាត់ថ្នាក់លេខ២ ក្នុងអាស៊ានអំពីចំនួនស្ត្រីចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាព របស់អ.ស.ប.។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានលើកឡើងអំពីការគាំទ្រយ៉ាងមុតមាំរបស់ អ.ស.ប. ជួយដល់កម្ពុជាក្នុងការអនុវត្តការប្តេជ្ញាចិត្តរបស់ខ្លួនលើសកម្មភាពអាកាសធាតុ និងក្នុងការរៀបចំសេចក្តីព្រាងច្បាប់ និងគោលនយោបាយផ្សេងៗ ព្រមទាំងគោលការណ៍ណែនាំបច្ចេកទេស ដើម្បីបង្កើនការបំពេញមុខងាររបស់ស្ថាប័នសាធារណៈ និងការអនុវត្តសិទ្ធិមនុស្ស។

**ឯកឧត្តម ប្រាក់ សុខុន** និងលោកស្រី Pauline Tamesis ក៏បានពិភាក្សាពីការពង្រឹងកិច្ចសហប្រតិបត្តិការអាស៊ាន-អ.ស.ប. និងការចូលរួមរបស់ឯកឧត្តមអគ្គលេខាធិការអ.ស.ប.ក្នុងកិច្ចប្រជុំកំពូលអាស៊ាន-អ.ស.ប.លើកទី១២ ដែលនឹងប្រារព្ធឡើងក្នុងទម្រង់រូបវន្ត (physical format) ក្នុងប្រទេសកម្ពុជានៅឆ្នាំនេះ ក្រោមភាពជាប្រធានអាស៊ានរបស់កម្ពុជា ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងអំពីវិស័យមួយចំនួនដែលត្រូវយកចិត្តទុកដាក់នៅក្នុងកិច្ចប្រជុំកំពូល រួមមានក្របខណ្ឌការស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន ការបន្សុីគ្នារវាងទស្សនៈវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០២៥និងការអភិវឌ្ឍប្រកបដោយចីរភាព ជាមួយនិងរបៀបវារៈគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ការការពារបរិស្ថាន ការលើកកម្ពស់កិច្ចសហប្រតិបត្តិការលើវិស័យមីន ពលករទេសន្តរប្រវេសន៍ ជាដើម។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានរំលឹកពីទស្សនៈកិច្ចលើកទីមួយរបស់ឯកឧត្តមទៅកាន់ប្រទេសមីយ៉ាន់ម៉ាក្នុងនាមជាប្រេសិតពិសេសរបស់ប្រធានអាស៊ាន ក្នុងការជួយមីយ៉ាន់ម៉ាចាកចេញពីវិបត្តិបច្ចុប្បន្នរបស់ខ្លួន និងការផ្តល់ជំនួយមនុស្សធម៌ដល់ប្រជាជនមីយ៉ាន់ម៉ា។

លោកស្រី Pauline Tamesis បានកោតសរសើរអំពីការអភិវឌ្ឍផ្នែកសង្គម-សេដ្ឋកិច្ច ការរួមចំណែកដ៏សំខាន់ដល់កិច្ចខិតខំថែរក្សាសន្តិភាពអន្តរជាតិរបស់កម្ពុជា ភាពជោគជ័យរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងជម្ងឺកូវីដ-១៩ ដែលឈានទៅរកការបើកប្រទេសពេញលេញឡើងវិញ និងបានគូសបញ្ជាក់ពីការគាំទ្រដ៏រឹងមាំរបស់អ.ស.ប.សម្រាប់ការបង្កើតយុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ខ្លួន។ លោកស្រី ក៏បានសម្តែងការកោតសរសើរ និងការដឹងគុណសម្រាប់កិច្ចសហប្រតិបត្តិការ ការគាំទ្រ និងការសម្របសម្រួលដែលបានផ្តល់ជូនក្រុមទីភ្នាក់ងារអ.ស.ប.ប្រចាំកម្ពុជា ដោយរាជរដ្ឋាភិបាល ជាពិសេសក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៕

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២